Khmer Story Lovers

# បញហេណៈ

— ទីចាត់ការនៃក្រុមអ្នកនិពន្ធមាតុភូមិផ្ទះលេខ ២៥ ផ្លូវលេខ ២៨៩ ជីឡូត៍លេខ ២៩៤ បឹងកេងកង សង្កាត់លេខ ៥ ក្រុងភ្នំពេញ —

## ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ



អ្នកប្រែសម្រួល: អ.គឹមសាន

តម្លៃ ២៥ រ

ផ្សាយចេញពីក្រុមអ្នកនិពន្ធ
«មាតុភូមិ»
ភ្នំពេញ

លេខ ៤៣

យាយស៊ីបន្លឺផ់បន្តិចទើបបន្តថា: ម៉ែអន្ទរគាត់វង់ចាំ ដោះស្រាយទាំងអស់គ្នា គាត់បបេសណាស់ពោលថា :

–ខ្ញុំមានកំហុសធំធ្ងន់ចំពោះក្រុមបក្សយើង ខ្ញុំត្រូវស្លាប់សម្រាប់ក្រុមយើងវិញ ធ្វើបែបនេះទើបប្រពន្ធកូនខ្ញុំ កូនប្រសា ចៅទឹងចៅប្រសា ព្រមទាំងសិស្សគណទាំងអស់អាចរស់នៅតទៅទៀត ។

ពោលចប់ឪពុកឯងលូកដៃយ៉ាងរហ័សចុចជីពចរម៉ែ ដាប់រកគេចមិនទាន់ ៗ រួចហើយគាត់ដណ្ដើមផ្កាកស្លាន់រត់ចេញទៅបាត់ ។ ពេលនេះប្រហែលទៅឆ្ងាយហើយ...

ប៉ាយវាន់ផានស្ដាប់ចប់ពោលថា :

–ម៉ែអើយ, កុំឲ្យពុកទៅអី ព្រោះពុកចាស់ជរា សុខភាពមិនសូវបរិបូណ៌ទេ... ទុកឲ្យកូនទៅជំនួសវិញ ។

យាយស៊ីរលាស់ដៃភាវ គំហកដាក់កូន :

– យី រហូតក្បាលឯងកញ្ចាស់ប៉ុណ្ណឹងហើយ, ឯងមិនទាន់ស្គាល់ចិត្តថ្លើមឪពុកទេឬ ?

ពោលចប់យាយស៊ីដើរចេញមក, ប៉ាយវាន់ផានដើរតាមសួរ:

– ម៉ែ, ម៉ែ...ចង់... អញ្ជើញទៅណាហ្នឹង ?

យាយស៊ីតបព្រងើយ :

-ម៉ែនជានាយក្រុមព្រះរាជទិព្យត្រូវបានករណីយកិច្ចទៅផ្ញើល្បៀងនៅកោះឡុងមុំដែរណា !

ប៉ាយវ៉ាន់ជានច្រូលច្របល់ពេញទុក តិនត្រូនស្ដើប្រែះមិនដឹងសម្រេចចិត្តយ៉ាងណាសោះ ទីបំផុតគាត់ប្ដេជ្ញាថា : ត្រូវទៅប្ដូរស្លាប់រស់ឯកោះឡុងមុំទាំងអស់គ្នាតែម្ដងចុះ ។

## វគ្គទី ៣៩

## បបរខែកត្តិក

ថ្ងៃប្រាំកើតខែកត្តិក យាយស៊ុំបាននាំប៉ាយវ៉ាន់ជាង, ស៊ុំឈីន, វ៉ុនយូ, ស៊ុំផាន, កាស៊ុំ ឈឹងជីសេ, ឈីជីហាន់និងលានជីឌិន ចេញដំណើរទៅកាន់ភូមិនេសាទមួយនាទន្លេណានហៃ ។

នៅលើផ្លាកបញ្ញាម្ចាស់មានចារខែថ្ងៃព្រមទាំងទីកន្លែងណាត់ជួបគ្នាស្រាប់, បើតាមស្នានប្រហែ[ល] ផ្លាកស្លាក់ទាំងអស់មិនដូចគ្នាទេ, ព្រោះយាយស៊ុំនាំកូនចៅទៅដល់នោះគ្មានឃើញប៉ាយជីតាយម្ចាស[់] ក្រុមរូបណាសោះ, សូម្បីតែអ្នកស្រុកឬកូនក្មេងមួយក៏គ្មានជួបដែរ ។

កាលយាយស៊ុំ ចុះពាក់ភ្នំទឹកកកមក, គាត់បានទុកដាក់កិច្ចការសព្វសារពើឲ្យចិនវ៉ាន់ជុង កា[...] កាប់ជាបណ្ដោះអាសន្នដោយមានវ៉ុនវ៉ាន់យ៉ឺនិងហូវ៉ាន់យានអមសងខាងជួយមើលការខុសត្រូវ ។ បា[...] ជាគាត់នាំពួកឈឹងជីសេទៅដែរព្រោះគាត់ខ្លាចអ្នកទាំងបីរួមគំនិតក្បត់ដណ្ដើមដំណែងនាយក្រុមដូចមុន [...] ឯលាវជីលីបាក់ជើងមានរបួសធ្ងន់ត្រូវក្លាយជាជនពិការមិនអាចប្រព្រឹត្តអំពើក្បត់បានទៀតឡើយ ។

អ្នកទាំងអស់គ្នាទៅដល់កន្លែងណាត់ ក៏ចូលសម្រាកក្នុងផ្ទះស្បូវមួយក្នុងភូមិនេសាទ ។ ដល់ពេល ព្រលប់ ទើបឃើញជនម្នាក់ពាក់អាវលឿងកាន់ច្រវាដើរចូលមកក្នុងភូមិស្រែកថ្កូន ១ ថា:

-ខ្ញុំបាទទទួលបញ្ជាពីលោកម្ចាស់កោះឡុងមុំ សុំអញ្ជើញលោកនាយក្រុមស៊ុំខាងក្រុមឈានលួ[...] ទាំងអស់គ្នាឲ្យសម្រេចនូវស្រាតែនកប្រាំពីរឡើងមកមើល ។ បុរសអាវលឿងដើរទៅជិតស៊ុំផាន[...] លំអោនកាយសួរ:

- លោកប្រហែលជានាយក្រុមស៊ុំហើយមែនទេ ?

ស៊ុំផានងក់ក្បាល :

- មែន ! ចុះលោកមាននាមថាម៉េចដែរ ?

- ខ្ញុំបាទមានត្រកូលឡុង, សុំអញ្ជើញលោកនាយក្រុមស៊ុំចេញដំណើរ ។

ស៊ីផឆានស្មើ :

– ខ្ញុំបាទមានមិត្តភក្តិប៉ុន្មាននាក់នេះ ចង់ទៅកំសាន្តកោះឡូនមុរបស់លោកផងបានឬទេ ?

–រឿងនេះដូចជាពិបាកបន្តិចហើយ ព្រោះទូកខ្ញុំតូចពេកផ្ទុកមនុស្សច្រើនមិនបានទេ ។ ម៉្យាងទៀតលោកម្ចាស់កោះបញ្ជាមកដាច់ណាត់, ឲ្យមកទទួលតែលោកនាយក្រុមស៊ីម្នាក់គត់, បើលើសពីម្នាក់ខ្លួនខ្ញុំត្រូវលិចហើយក្បាលខ្ញុំនឹងត្រូវជ្រុះពីស្មាទៀត ។

យាយស៊ីធ្វើពុះ ! ពោលកាត់ :

–យើងមកដល់នេះហើយមិនបណ្តោយតាមចិត្តឯងទេ !

ពោលចប់ផ្ទួនចាស់បង្កើរខ្លួនឈរកិតពីក្រោយជនអាវលឿង យាំងផ្លូវមិនឲ្យគេគេចខ្លួនបាន ។ ជននោះមិនរវល់អើពើនឹងយាយស៊ីទេ, គេញញឹមពោលទៅកាន់ស៊ីផឆានទៀត:

–ខ្ញុំបាទសុំនាំផ្លូវលោកនាយក្រុមស៊ី ! សុំអញ្ជើញ !

គេបែរក្រោយដើរទៅមុន ។ ស៊ីផឆាន, យាយស៊ី ព្រមទាំងគ្នីគ្នាគាត់ទាំងអស់ដើរតាមក្រោយស្អិត ។ ជនអាវលឿងចុះតាមប្រាំងដើរលើឆ្នេរខ្សាច់ដល់កន្លែងទុកកូនទូកគេ ។ ទូកនេះតូចមែនប្រវែងប្រហែលពីរម៉ែត្រប៉ុណ្ណោះ ឃើញថាជិះពីរនាក់ស្ទើរមិនបានផង កុំថាឡើយដល់ប្រាំនាក់ប្រមួយហ្វូង ។ ជនអាវលឿងពោល :

-បើអស់លោកចង់សម្លាប់ខ្ញុំឃើញថាងាយណាស់, តែបើលោកអ្នកណាស្គាល់ផ្លូវទៅកោះឡូនមុ សូមអញ្ជើញចុះទូកជាមួយលោកនាយក្រុមស៊ីជំនួសខ្ញុំចុះ ។

យាយស៊ីនិងស៊ីឈីងមើលមុខគ្នាឡេងឡង់មិនទឹកស្មានថាពួកកោះឡូនមុបាត់តែងការ ល្អិតល្អន់បែបនេះគ្រាន់តែលើសម្នាក់ក៏មិនបានដែរ ។ អ្នកណាក៏ស្គាល់ឈ្មោះកោះឡូនមុដែរ, ប៉ុន្តែសមុទ្រល្ហល្ហេវមើលកោះត្រើយមិនឃើញតើឲ្យកេកោះឡូនមុត្រង់ណា ? សូម្បីទូកឬសំពៅក៏មិនឃើញស្រមោលមួយដែរ ។

យាយស៊ីខឹងឆ្អួលយារដៃប្រុងទះកំទេចក្បាលជនអាវលឿងតែគាត់នឹកឃើញទាន់ ក៏ដកបេញហើយងាកទៅប្រាប់ស៊ីផឆាន :

–ចៅប្រុស , ឯងប្រគល់ផ្កាគបញ្ជាមកយាយ , ទុកឲ្យយាយទៅជំនួសឯងទើបយាយអាចស្ទាបជាមួយកញ្ចាស់ចក្ខុតបាន ។

បុរសកាវលឿនពោលភ្លាម:

–កុំ ! កុំ ! លោកម្ចាស់កោះបានបញ្ជាច្បាស់លាស់ណាស់ ឲ្យមកទទួលលោកនាយក្រុមស៊ឺ, បើ ខ្ញុំនាំមនុស្សខុសទៅមិនត្រឹមតែរូបខ្ញុំបាទទេដែលត្រូវស្លាប់នោះ , សូម្បីម្ដាយឪពុកប្រពន្ធកូនខ្ញុំក៏ លោកមិនទុកឲ្យគង់ជីវិតដែរ ។

យាយស៊ីសន្ទាប :

–ស្លាប់ក៏ស្លាប់ទៅ, គ្មានទើសក្បាលយើងទេ !

ភ្លាមនោះគាត់នឹកថាមិនទើសក្បាលយើងមែន, តែការណ៍តជននេះដែរទើបនឹករកមធ្យោបាយផ្សេង ទៀត, ពោលទៅកាន់ស៊ឺផាន:

– ស៊ឺទៅប្រុស, ឯងប្រគល់ដំណែងនាយក្រុមឈានល្ងួមកយាយវិញ, ដកបណា យាយជ នាយក្រុមឈានល្ងួហើយ, បុរសនេះឥតមានទោសថាទទួលមនុស្សខុសទេ ។

ស៊ឺផានទីទើរ, បុរសកាវលឿនឆ្លើយជំនួស:

– សេនាបញ្ជាចាំងពីរប្រាប់បានបញ្ជាក់ច្បាស់លាស់ហើយថាលោកនាយក្រុមឈានល្ងួ ជាយុវជនរូប ស្រស់សង្ហានៅក្មេងកម្លាំងមាន, មិនមែនជាជូនចាស់ទេ ។

យាយស៊ីស្រែកគំហក :

– អាហោលម្សៀត !

បុរសកាវលឿនសើចញញឹម ចុះទៅទាត់ទឹកស្រាវខ្សែទូកធ្វើព្រងើយ ។ យាយស៊ីតាល បំណោះដកដង្ហើមយូរប្រាប់ស៊ឺផាន:

– ណ្ហើយឯងទៅចុះ , តែចាំស្ដាប់បណ្ដាំគ្រូ ។

ស៊ឺផានពោលយ៉ាងគោរព:

– សូមអ្នកគ្រូមានប្រសាសន៍មកចុះ ។

–ត្រូវចាំឲ្យជាក់ណា ! បើមានឱកាសរត់គេចរួចត្រូវគេចមកវិញមុនតែម្នាក់ឯងបានហើយ កុំអាល វល់ជួយយកអាសារលោកតាឲ្យឱកាសល្អកន្លងហួសឮទេ ? នេះជាបញ្ហាដ៏តឹងរឹងបំផុតដែលឯងត្រូ ធ្វើតាមជាដាច់ខាត !

ស៊ឺផានមិនយាំងដណ្ដឹងសួរក្នុងចិត្តថា :

-ហេតុអីអ្នកគ្រូមិនឲ្យយើងជួយលោកតា ? គាត់ខឹងមិនទាន់បាត់ទេដឹង ?

ហាយស៊ីបន្ត :

-ឯងប្រាប់កញ្ចាស់នោះផងថា អ្នកគ្រូនៅចាំគាត់ត្រង់នេះចំនួនមួយខែគត់, បើដល់ថ្ងៃប្រាំបីកើតខែក្រោយគាត់មិនមកជួបគ្រូទេ គ្រូនឹងលោតទឹកសម្លាប់ខ្លួនហើយ ។- \ បើគាត់នៅរំពុករឿងគោះខ្យង់ខៀវយ៉ាងរលើលទៀត គ្រូមិនអត់ទុនគាត់ទេ ទោះស្លាប់ទៅជាខ្មោចក៏គ្រូនៅតាមចងពៀរគាត់ដែរ, ចាំទេ ?

ស៊ីផានងក់ក្បាលឆ្លើយបាទ ៗ អាស៊ីរដើរមកជិតនាយផ្តាំថា :

-បង... ខ្ញុំ... ខ្ញុំនៅចាំបងទីនេះដែរ, មួយខែគត់ណា !

ស៊ីផានសប្បាយចិត្ត តែបែរជាក្រៀមក្រំទៅវិញ :

- អូនមិនបាច់ធ្វើដូចលោកហាយទេ ៗ

-ទេៗ , ខ្ញុំត្រូវតែចាំបង ៗ

សម្លេងនាងតូចឆ្មារ តែមានភាពម៉ឺងម៉ាត់ណាស់ ៗ វុនយូដើរមកជិតមាណពពោលដោយស្រទន់ :

-កូន, សុំឲ្យកូនបានត្រឡប់មកវិញដោយសុខសាន្ត, យើងនៅរង់ចាំមើលផ្លូវកូនជានិច្ច ៗ

មាណពក្តុកក្តួលអួលកក់រំភើបចិត្តនឹងវាចាអ្នកស្រីជាអនេក ៗ នាយឆ្លើយភ្លាម :

-ខ្ញុំជានាយក្រុមឈានល្បីក្លៀវក្លា ប្រហែលពួកគេលែងឲ្យខ្ញុំមកជួបមុខអស់លោកវិញមែន ៗ ម៉្យាងទៀតបងសាននិងលីសែជាបងធម៌ខ្ញុំស្រាប់ ទោះមេបម្តាគាត់មិនបណ្តោយឲ្យខ្ញុំមានគ្រោះថ្នាក់ទេ ៗ

វុនយូងក់ក្បាលមួយៗ:

- សូមឲ្យទេវតាស្តាប់ឮសំដីកូនចុះ !

មាត់និយាយដូច្នេះ រីក្នុងចិត្តអ្នកស្រីនឹកថា :

- ក្មេងនេះឥតញញើតឬមន្ទិលសៅហ្មងលើអ្នកគុននិយមកាបសាហាវនិងទុច្ចរិតឡើយ ៗ បងធម៌របៀបហ្នឹងមិនគួរទុកចិត្តទេ លោកអើយ !

ប៉ាយភន់ជានទិតមកកាន់ដៃនាយជាប់ផ្តាំថា :

-កូនប្រុស , ចាប់ពីពេលនេះទៅយើងជាគ្រួសារតែមួយហើយ ។ លោកតាចាស់ជរាកម្លាំងខ្សោយ កូនត្រូវជួយការពារគាត់ផងណា !

ស៊ីផានឮគេហៅនាយ«កូនៗ»គ្រប់គ្នានាយសប្បាយផងអរផងមុខក្រហមឆ្អៅ ។ នាយឆ្លើយដោយគោរព :

-ខ្ញុំបាទនឹងចងចាំបណ្ដាំលោកគ្រូ ។

ក្នុងចំណោមនេះមានតែឈឹងជីសេ, ឈើជីមាន និងលាងជីជិនទេ ដែលសប្បាយខុសធម្មតា ។ គេនឹកវៀងខ្លួនថា :

- សាមសិបឆ្នាំមកហើយមានអ្នកក្លាហានប៉ុន្មានក្រុមទៅកោះឡុងមុប៉ុលើក , មិនដែលឃើញអ្នកណាត្រឡប់មកវិញសោះ ។ អាប្រមក់ឯងនេះមានដៃម្ភៃក្បាលបី បានជាសង្ឃឹមត្រឡប់មកជួបពួកយើងវិញ ?

ពេលនោះស៊ីផានគោរពលាអ្នកទាំងអស់ចុះតាមមាត់ច្រាំងដើរតម្រង់ទូកទូក ។ អ្នកអស់នោះក៏ជូនដំណើរនាយទៅដែរ ។ អាស៊ីវនិងអ្នកស្រីវ៉ុនយូនឹកស្រណោះមាណពរហូតហូរទឹកភ្នែករហាម ។ ស្រាប់តែយាយស៊ុយារដៃចង្អុលកំផ្លៀងជនពាក់អាវលឿងទាំងអស់ទំហឹង ព្រមទាំងគំហក:

-ឯងព្រហើនណាស់, ត្រូវប្រយ័ត្នម្ដងទើបភ្លឺភ្នែក ។

បុរសអាវលឿងឥតរវល់ទេ, គេលើកដៃស្ទាបថ្ពាល់អង្អែលហើយលោតឡើងជិះទូកធ្វើព្រងើយ ។ ស៊ីផានលំទោនកាយគោរពលាមួយដងទៀតទើបឡើងជិះទូកតូច ។ ទូកនេះតូចមែន , ត្រូវទម្ងន់មនុស្សពីរនាក់ក៏លិចស្រឹមនៅសល់ ប្រហែលមួយចំអាមលើផ្ទៃទឹក ធ្វើដំណើរលើសមុទ្រគួរឲ្យញញើតណាស់ ។ ប៉ុន្តែផ្លូវនេះជាផ្លូវឆ្ងាយទើបមិនសូវមានខ្យល់តាមដៃសមុទ្រ , បើពុំនោះសោតកូនទូកច្បាស់ជាត្រូវលកបោកបក់បែកប្លុលិចពុំខាន ។ កោះឡុងមុណាត់ឲ្យអ្នកក្លាហានមកជប់លៀងបវរនេះកត្តិកដោយហេតុទឹកសមុទ្រស្ងប់ស្ងាត់ទេដឹង ?

ជនអាវលឿងលើកច្រវាគាស់ទូកតូចចេញចាកកំពង់ដល់ទឹកជ្រៅទើបបំបែរក្បាលទូកតម្រង់ទិសខាងត្បូងហើយបង្ហូតក្ដោងមួយតូចពណ៌លឿងដែរ ។ ទូកតូចត្រូវក្ដោងជួយយោងក៏លឿនលយកាន់តែតូចទៅ ។ ...

ស៊ីផានងាកមើលយាយស៊ុ, ក្រស៊ីវ,ប្ដីប្រពន្ធស៊ុឈឹងនិងអ្នកដទៃទៀតរហូតផុតកន្ទុយភ្នែក ។

កនៅលើគោកឈរសម្លឹងសមុទ្ររហូត ដោយម្នាក់ៗ នឹកឃើញប្លែកៗពីគ្នា ។

កូនទូកធ្វើដំណើររហូតយប់ទើបបំបែរក្បាលទៅទិសអគ្នេយ៍ ។ គេបន្តដំណើរបីថ្ងៃបីយប់ទៀតតាមផ្លូវដដែល, ដល់ថ្ងៃទីបួនពេលថ្ងៃត្រង់ ត្រូវនឹងថ្ងៃទីប្រាំបីកើតខែកត្តិក ទើបដនអាវឿនចង្អុលណុចខ្មៅមួយកណ្ដាលផ្ទៃសមុទ្រប្រាប់ស៊ីផធានថា :

- នុះជាកោះឡង់មុហើយ ។

មាណពសម្លឹងតាមគ្មានឃើញអ្វីច្បាស់លាស់សោះ តែនាយបុកពោះកឹបៗ . . .

ទូកតូចលឿនលយទៅមុខប្រហែលមួយម៉ោងក្រោយទើបនាយឃើញជាកោះមួយខ្ពស់ ត្រដែតានចំណុំភ្នំដុះពីលើប្រកបដោយព្រៃឈើខៀវស្រងាត់ ។ ដនអាវឿនអែបទូករកកោះនោះហើយពោល :

- សូមលោកនាយក្រុមស៊ីអញ្ជើញឡើងគោក ។

ទីនេះជាវាលខ្សាច់ខាងទិសខាងត្បូង ។ នៅខាងកើតមានទូកធំចតតម្រៀបគ្រាប្រមាណសាមសិប ។ ស៊ីផធានឹកថា :

- យី មានទូកច្រើនណាស់តើ ! បើមិនស្លាប់លើកោះ យើងមានផ្លូវលួចទូកមួយរំដោះខ្លួនរត់រួចដែរ ។

នាយលែងភ័យលោតឡើងគោកភ្លាម ។ បុរសអាវឿន ក៏កាន់ខ្សែទូកលោតចុះមកចងភ្ជាប់នឹងដុំថ្មមួយដែរ ។ បន្ទាប់មកគេហូតស្នែងមួយតូចផ្លុំ ព្រុ គ្រលួច ។ មិនយូរប៉ុន្មានឃើញមនុស្សបួននាក់ពាក់អាវលឿនដូចគ្នាដើរមកដល់ ។ គេម្នីម្នាបន្ទន់កាយគោរពស៊ីផធានធ្វើការគំរូ:

- លោកម្ចាស់កោះនៅរង់ចាំលោកនាយក្រុមឯបន្ទប់កិត្តិយស , សូមលោកនាយអញ្ជើញចូលតាន ។

ស៊ីផធានចង់ដឹងដំណាំង ប៉ុយដីចាយណាស់ក៏សួរ:

-លោកគ្រូធំខាងភ្នំទឹកកកអញ្ជើញមកដល់ហើយឬនៅ?

បុរសអាវឿនម្នាក់ទំនង់មេគេឆ្លើយ :

-យើងខ្ញុំមានមុខងារតែត្រូវទទួលលោកនាយក្រុមស៊ីប៉ុណ្ណោះ , ឥតដឹងរឿងអ្វីទៀតទេ ! សូម

Khmer Story Lovers



លោកអញ្ជើញសិនទើបសាកសួរអ្នកឯទៀតបាន ។

ពេលចប់គេនាំផ្លូវទៅមុន, ស៊ីផានដើរតាមក្រោយ រីជនអាវលឿងបួននាក់ទៀតដើរពីចម្ងាយ ។

ស៊ីផានសង្កេតទិដ្ឋភាពតាមផ្លូវឥតមានប្រហែស ថែមទាំងចំចំណាំចង់ចាំគ្រប់ច្រកល្ហក ការពារក្រែងមានសំណាងរត់ទៅវិញបាន ។

មុនដំបូងគេដើរចូលច្រកភ្នំមួយមានដើមឈើអមសងខាងផ្លូវ, រួចដល់ផ្លូវបត់តូចបន្តិច ។ នៅខាងក្នុងឃើញទឹកជ្រោះហូរធ្លាក់ពីលើភ្នំប៉ះផ្ទាំងថ្មបែកពពុះសព្រាត ។ ផ្លូវនេះកាន់តែខ្ពស់ឡើងៗ គេដើរបត់បែនមួយសន្ទុះធំទៀតទើបដល់ទីបំផុតគឺផ្លូវទាល់មានទឹកជ្រោះហូរធ្លាក់ពីលើភ្នំត្រង់ច្រកពទឹកតែម្ដង ។ បុរសដែលនាំផ្លូវលើកដៃទាញយកអាវមួយធ្វើពីកំណាត់កៅស៊ូ ចេញពីក្រោយគល់ឈើហុចឲ្យស៊ីផាន:

- បន្ទប់កិត្តិយស យើងខ្ញុំស្ថិតនៅក្នុងទឹកជ្រោះនេះឯង គឺជាកន្លែងតែមួយគត់ដែលត្រជាក់ជាងគេនៅលើកោះនេះ ។ សូមលោកនាយក្រុមពាក់អាវនេះកុំឲ្យទទឹក ។

ស៊ីផានទទួលអាវកៅស៊ូមកពាក់ស្រួលបួលតាមគេសុំ ។ បុរសអាវលឿងដើរទៅដល់ទឹកជ្រោះ ស្រាប់តែលោតផ្លោតចូលក្នុងនោះបាត់, ស៊ីផានមិនរុញរាក៏លោតទៅតាមភ្លែត !

ខាងក្រោយផ្ទាំងទឹកជ្រោះ គឺជាផ្លូវមួយលុងក្នុងភ្នំយ៉ាងចម្លែក ហាក់ដូចស្នាដៃធម្មជាតិសុទ្ធសាធ ព្រោះមានកន្លែងខ្លះបញ្ឆៀត កន្លែងខ្លះទូលាយ ។ នៅសងខាងគឺចង្កៀងច្រើនដុតបំភ្លឺល្មមមើលមុខគ្នាឃើញច្បាស់ ។ ស៊ីផានដើរតាមបុរសពាក់អាវលឿងកាត់ផ្លូវក្រវិចក្រវៀនចំនួនជាច្រើនទៀតរហូតដល់ពេលឮទឹករលកបោកថ្មគ្រាំងៗយ៉ាងច្បាស់ ។ ទំរាំមកដល់នេះ, មាណពត្រូវកាត់ផ្លូវបត់បែនមិនដឹងជាប៉ុន្មានទេ, នាយកប៉េតសក្ខុនផងមិនហ៊ានឲ្យភ្លេចចំណុចត្រង់ណាឡើយ ។ ប្រហែលពីរគីឡូម៉ែត្រទើបមកដល់ទ្វារថ្មកងមូលមានអក្សរធំៗពីលើ ។ មាណពសួរថា:

-នេះជាបន្ទប់កិត្តិយសឬ ?

ជនអាវលឿងងាកមកឆ្លើយ

- ប្របាទ !

ហើយឆ្ងល់ក្នុងចិត្តថា :

- អក្សរប៉ុណ្ណាប៉ុណ្ណឹមម៉េចចាំបាច់សួរទៀតហ្ន៎ ! គាត់នេះមិនចេះអក្សរទេដឹង ?

បុរសស្ពានមានខុសឯណា ? ស៊ីផឆានមិនចេះអក្សរមែនទើបសួរគេ ។ ចូលផុតទ្វារថ្មនេះ គឺជាផ្លូវស្អាតក្រាលកម្រាលកំណាត់ ។

បុរសពាក់អាវលឿងនាំមាណពដើរចូលរូងភ្នំមួយខាងឆ្វេងដៃហើយពោល :

– សូមលោកនាយក្រុមសំរាកទីនេះបន្តិចសិន, ចាំដល់ពេលជប់លៀងទើបលោកម្ចាស់កោះឲ្យគេមកអញ្ជើញ ។

ស៊ីផឆានដើរចូលរូងថ្មដែលមានតុកៅអីគ្រប់គ្រាន់ព្រមទាំងទៀនភ្លឺព្រោងព្រាត ។ មិនយូរប៉ុន្មាន នាយឃើញក្មេងម្នាក់លើកចំណីអាហារមួយថាសនិងទឹកតែមួយប៉ាន់មកដាក់លើតុសម្រាប់នាយ ។ គ្រាន់តែក្រឡេកឃើញម្ហូបចំណីស៊ីផឆាននឹកដល់បណ្តាំស៊ុយឈីងភ្លាម ។ ស៊ុយឈីងបានរៀបរាប់ប្រាប់នាយថា ក្នុងរយៈពេលសាមសិបឆ្នាំកន្លងមកនេះអ្នកក្លាហានរាប់មិនអស់ ត្រូវកោះឡុងមុអញ្ជើញពិសាបបរខែកត្តិក , តែមិនដែលឮអ្នកណាមួយបានវិលទៅផ្ទះវិញសោះ ។ បើតាមគាត់យល់ នៅកោះឡុងមុប្រហែលសម្បូរអ្នកខ្លាំងពូកែណាស់ ប៉ុន្តែទោះបីយ៉ាងណាក៏គេមិនអាចសម្លាប់អ្នកក្លាហានពាន់ហួង ១ ដែរ ព្រោះអ្នកអស់នោះសុទ្ធសឹងជានាយក្រុម ។

គាត់ហ៊ានទាយថាពិតជាអ្នកម្ចាស់កោះឡុងមុប្រើល្បិចថោកទាបមានគ្រឿងយន្ត, អន្ទាក់ឬថ្នាំពិសពុលជាមិនខាន ។ គេហ៊ានប្រកាសថាអញ្ជើញទៅជប់លៀងបបរប្រាកដជាគ្រោះថ្នាក់មិនស្ថិតនៅក្នុងបបរទេ, យើងត្រូវប្រយ័ត្នចំពោះម្ហូបចំណីផ្សេងឬស្រា,ទឹកតែវិញទើបហៅថាគ្រាន់បើ ។ ប៉ុន្តែអ្នកគុននិយមភាគច្រើនមិនមែនល្ងង់នឹកមិនឃើញការឆោយបែបនេះទេ មុននឹងទៅកោះឡុងមុ គេច្បាស់ជាដើររកថ្នាំបន្សាបពិសយកតាមខ្លួនដែរ, តែមិនឃើញបានការអ្វីសោះ ។

ស៊ុយឈីងផ្តាំផ្ញើឲ្យមាណពប្រយ័ត្នប្រយែងមែនទែន ក្រែងទេពតាជួយអាចគេចផុតគ្រោះថ្នាក់ ព្រោះនាយស្លូតបូតស្មោះត្រង់ណាស់ ។

ស៊ីផឆាននឹកឃើញបណ្តាំចាស់ទុំនិងមិត្តភក្តិគ្រប់ម៉ាត់, តែម្ហូបចំណីអស់នេះពោលក្លិនឈ្ងុយឈ្ងប់ធ្វើឲ្យក្លួរពោះគ្រួកៗ ស្រក់ទឹកមាត់ប្រោក តើអត់ទ្រាំម្តេចបាន ? ម្យ៉ាងទៀតប៉ុន្មានថ្ងៃនេះនាយហូបតែបាយនិងត្រីងៀត ចាល់តែធុញទៅហើយ ។ នាយនឹកថា :

–បើមកដល់កន្លែងស្លាប់ហើយឃ្លានម៉្លឹងៗអត់ទ្រាំឯណាបាន ។ បើគេចង់សម្លាប់នឹងថ្នាំពុល គេអាចដាក់បានរាល់ពេល ។ យើងទំអត់ថ្ងៃនេះគង់ចៀសមិនផុតពីថ្ងៃស្អែកដែរ ។ លោកបង

Khmer Story Lovers

ជានសាទនិងលីសៃ៊បានស្បថស្បែជាមួយយើងថារួមសុខទុក្ខរហូតថ្ងៃស្លាប់, បើគាត់បណ្ដោយឲ្យយើងទទួលៈគ្រោះថ្នាក់ពិតជាគាត់មិនសប្បាយចិត្តទេ...

មាណពទឹកសព្វគ្រប់ទើបចាប់ផ្ដើមបរិភោគនិចណាំហើយផឹកទឹកតែអស់កន្ទះប៉ាន់ផង ។ បន្ទាប់ពីនោះនាយអង្គុយសម្រាកក្នុងរូងភ្នំប្រហែលពីរម៉ោងស្រាប់តែឮសម្លេងកញ្ចែប្រេចៗគ្រប់ទិស ។

ជនអាវលឿងដែលនាំផ្លូវនាយមកដល់ទីនេះបានចូលមកអញ្ជើញនាយថា :

-លោកម្ចាស់កោះសុំអញ្ជើញលោកចូលរួមពិធីជប់លៀង ។

ស៊ីផានក្រោកក្រេះទាញខោអាវស្រួលបួលហើយដើរតាមគេចេញទៅ ។ ស្គរកញ្ចែកាន់តែលាន់ខ្លាំងឡើងលាយឡំជាមួយស្គរស្គរទូងៗផង ។ គេដើរកាត់រូងថ្មផ្លូចៗគ្នាជាច្រើនទើបដល់បន្ទប់ថ្មមួយយ៉ាងធំភ្លឺចិញ្ចាចដោយសារទៀនធំៗ ហាក់ដូចនៅកណ្ដាលវាលក្រោមពន្លឺថ្ងៃ ។ បន្ទប់ថ្មនេះធំទូលាយណាស់, ទោះមានរៀបតុកៅអីរាប់រយក៏នៅកន្លែងទំនេរសំរាប់ឈរដែរ ។

ស៊ីផានឃើញជនអាវលឿងរាប់រយនាក់ដើរខ្វាត់ខ្វែងរៀបចំទីកន្លែង អញ្ជើញភ្ញៀវអង្គុយយ៉ាងគួរសម ។ មាណពឃើញសុទ្ធតែភ្ញៀវគ្នាឯងអង្គុយត្រៀបត្រា ។ នាយបោះភ្នែកមួយត្រួសរកមើលប៉ាយជីតាយ ។ អ៊ុះ ! តាចាស់អង្គុយត្រង់តុមួយនៅឯនាយ, ពុកមាត់គាត់សក្បុស ហុកពាអង់អាចមាឌធំខ្ពស់ជាងគេក្រឡេកភ្លាមឃើញភ្លាម ។

កាលស៊ីផានជួបគាត់លើភ្នំទឹកកកក្នុងទីឃុំឃាំងនោះនាយមើលមុខគាត់មិនសូវច្បាស់ទេ, ពេលនេះភ្លឺថែសទើបនាយគោតគោរពគាត់ជាព្រឹទ្ធាចារ្យ, បីដូចគេគោរពរូបអ្នកតាក្នុងវត្តអារាមដូច្នោះឯង ។ នាយខំប្រជ្រៀតហ្វូងមនុស្សដើរទៅរកគាត់ពោលភ្លាមថា :

-លោកតា, ខ្ញុំមកដល់ហើយ !

ក្នុងបន្ទប់ធំទូលាយមានមនុស្សច្រើនមែន, ប៉ុន្តែសេនាកោះឡុងមុំដែលមានការៈទទួលភ្ញៀវរាំនិយាយគ្នាតិចៗបំផុត, រីភ្ញៀវទាំងអស់សុទ្ធតែជឿខ្លួនថាមកស្លាប់នៅពេលបន្តិចនេះក៏ព្រួយបារម្ភ មុខស្រងូតដូចគ្នា គ្មាននរណាចង់និយាយស្ដីអ្វីឡើយ ។ កាលបើឮស៊ីផាននិយាយខ្លាំងៗឥតញញើតកោតក្រែងដូច្នេះ, អ្នកណាក៏ងាកមើលនាយដែរ ។

ប៉ាយជីតាយធ្វើហ៊ុះ, បន្ទោស:

-អាខ្មោចយក៍ ! ឯងមិនចង់ឲ្យជីតាមានទៅនឹងគេទេឬ ?

ស៊ីផានស្រឡាំងកាំងមួយសន្ទុះ ទើបយល់ថាពីតាចាស់បន្ទោសនាយមកស្លាប់លើកោះនេះ លែងរស់នឹកនារៀបការជាមួយអាស៊ីវ ។ នាយពោលទៀតថា :

-លោកតា១ , លោកយាយនៅចាំលោកតាឯមាត់សមុទ្រក្នុងភូមិនេសាទមួយ ។ គាត់ថាគំរប់មួយខែបើលោកតាមិនត្រឡប់ទៅវិញទេ គាត់ ... គាត់ ... នឹងលោតទឹកសម្លាប់ខ្លួនហើយ ។

ប៉ាយឌីតាយជ្រួញចិញ្ចើម :

-ម៉េច? យាយឯងមិនទៅកោះខ្យងខៀវទេឬ?

-កុំនិយាយរឿងហ្នឹងលោកតា ។ លោកយាយព្រួតគាត់ខឹងណាស់ណា ! ប្រយ័ត្ន, គាត់ជេរលោកតា···ជេរថា...

-ថាយ៉ាងម៉េចទៅ ?

-គាត់ថាលោកតាជាកញ្ចាស់ចំកួត ! ខ្មោចទីងមិនហួសបួនខូចទាំងមាត់ខូចទាំងសំដី, កាលណាជួបមុខគាត់ត្រូវយកកាំបិតកាប់ចិញ្ច្រាំឲ្យខ្ទេចទើបអស់ចិត្ត ។

ប៉ាយឌីតាយសើចហាសៗគងរំពង :

-មែន ! មែន ! ធ្វើអីចឹងទើបត្រូវ !

ខណៈនោះស្រាប់តែឮមនុស្សម្នាក់យំហ៊ូៗ នៅកៀនជញ្ជាំង ព្រមទាំងពោលដាច់ៗថា :

- គេជេរយើងអីចឹងមែនឬ ? តើយើងធ្វើអីគេខុសបានជាគេខឹងម្ល៉េះ ? យើងស្មោះត្រង់អស់ប៉ុណ្ណឹងហើយ, រង់ចាំដល់ចាស់សក់ស្កូវជិតចូលរណ្តៅហើយមិនទាន់យកប្រពន្ធទៀត... ហ៊ូ ! ហ៊ូ . ចិត្តគេរឹងដូចថ្ម... សូម្បីកោះខ្យងខៀវក៏គេមិនខ្វល់ទៅជាន់ផង. . ហ៊ូ...ហ៊ូ...

ស៊ីផានងាករកប្រភពសម្លេងឃើញទីងមិនហួសបួន ក្រាបលើតុយំខ្សឹកខ្សួលញ័រញាក់ស្មាដូចកូនក្មេង នាយនឹកថា :

- តាទីងមកកាន់ទីនេះដែរហ្ន៎ ! ចំណាស់ហ្នឹងហើយនៅស្រែកយំកណ្តាលពលទៀត , មិនចេះខ្មាសគេទេឬ ?

ទីងមិនហួសបួនមានចរិតបែបនេះតាំងពីដើមមក; តែចង់ធ្វើអីយល់ថាត្រូវធ្វើម៉េចគាត់ធ្វើភ្លាម, មិនសូវចេះរើរល់នឹងចិត្តថ្លើមអ្នកដទៃទេ ដូចយ៉ាងគាត់ទៅរកដណ្តើមយាយស៊ុំពីក្តួនទឹកកក ដើម្បីយកទៅដាក់លើកោះខ្យងខៀវរបស់គាត់ជាដើម ។

ពេលនេះគាត់មកស្លាប់លើកោះឡង់មុតាំងសោកស្ដាយយាយស៊ី, ដល់ព្រឹកផ្ចាំពេលវេលានេះ គាត់ទ្រាំមិនបាន, ឈឺចិត្តណាស់ទើបយកណ្ដាលកល ។ ប្រសិនបើលើពេលធម្មតា អ្នកគុននិយមតាំងអស់ច្បាស់ជានាំគ្នាសើចចំអកឲ្យគាត់ហើយ ។

ពេលនេះគេបែរជាចង់យំតាមគាត់ឲ្យអស់ចិត្តទៅវិញ, ម៉្លោះហើយគេនៅស្ងៀម យំក៏មិនចេញ សើចក៏មិនរួច ។

អ្នកក្លាហានតាំងអស់ដែលមកជួបជុំក្នុងបន្ទប់នេះសុទ្ធសឹងធ្លាប់ហែលឆ្លងពិភពគុន ស្គាល់ការប្រយុទ្ធពេលមិនរស់ សឹងជាគេរស់នៅជាមួយផាវគាំបិតទៅហើយ, គ្មាននរណាញញើតចំពោះការស្លាប់រស់ឡើយ ។ ប៉ុន្តែបើស្លាប់ក្នុងឆាកប្រយុទ្ធគេយល់ថាជាការធម្មតាសម្រាប់អ្នកគុននិយមខ្លួនទៅ, ដល់មកស្លាប់លើកោះឡង់មុគេញញើតគ្រប់គ្នា បុកពោះបើស្ទុកព្រោះមិនដឹងស្លាប់ដោយរបៀបណា . . .

ក្នុងបរិយាកាសស្ងាត់ច្រៀបនេះស្រាប់តែព្រុសម្លេងស្ត្រីម្នាក់បន្ទឺឡើងយ៉ាងសោះកក្រោះមកពីនាយ :

- ហ៊ឺ ! ស្មោះស្មគ្រអស់ហើយហ្ន៎ ! ចាស់ស្ពាវសំព្រោងមិនទាន់យកប្រពន្ធទៀត ! ហាស ១.. ចិនមិនហួសប្អូន មិនបេះទ្រូងសនរណាមែន ! ប៉ុស្មោះត្រង់ដេកចាំតែស៊ីសាវឈ្មួយហេតុអីឯងទៅបង្កើតកូនស្រីមួយឲ្យបងយើង ?

រំពេចនោះចិនមិនហួសប្អូនងើបមុខពីលើតុមុខក្រហមឆាំង ស្ទុះក្រោកឈរស្រែកសួរ :

- ឯង...ឯង...ម៉េចដឹង ?

ស្រីនោះសួរចំអក :

- គេជាបងស្រីបង្កើតរបស់យើង, ម៉េចមិនឲ្យយើងដឹង ? ឥឡូវកូនស្រីនោះឯណា ? ស្លាប់ឬរស់ ?

ព្រះសូរដាំង ! ហើយប្រាវ ! គឺចិនមិនហួសប្អូនដាក់គូថលើកៅអីដោយអស់សន្ទុះមុខខ្លាំងពេកហួតបាក់ជើងកៅអីតាំងបួន ។ ស្ត្រីដែលគំហកសួរ :

- កូនស្រីនោះនៅឯណា ? រស់ស្លាប់ឬរស់ ? ប្រាប់ភ្លាមមក:

ចិនមិនហួសប្អូនពោលតិចៗ:

- យើងមិនដឹងទេ ។

- ហ៊ឺះ ! ពេលបងស្រីយើងហៀបផាច់ខ្យល់គាត់បានផ្ដាំយើងឲ្យទំរេកឯងដើម្បីយកកូន ស្រីនោះ

មកចិញ្ចឹមថែរក្សាណា៎ ! ហ៊ឺះ ! ឯងថែមខ្មៅពេកណាស់, បំផ្លាញអនាគតបងស្រីយើងហើយទៅដេកចាំប្រពន្ធគេទៀត ! កញ្ចាស់អប្រិយ !

ទីងមិនហួសបួនទប់កម្លាំងស្ទុះក្រោកឈរវិញយ៉ាងប្រញាប់មិនឲ្យដួលបះជើងទាន់ ។ ស្ត្រីនោះស្រែកសួរយ៉ាងសាហាវទៀតថា:

- កូនស្រីនោះស្លាប់ឬរស់ ? ឬទេ ?

តាចាស់តបសម្លេងអួលៗ:

-កាលម្ភៃឆ្នាំមុនវានៅរស់ , ... ឥឡូវនេះមិនដឹងទេ ។

-ហេតុអីឯងមិនតាមរកវា?

ទីងមិនហួសបួនអួលបំពង់កឆ្លើយថា :

-អ៊ី ... នៃ ... មិនហ៊ានរកទេ ។

ស៊ុផានបោលភ្នែកក្រឡេកមើលស្ត្រីម្ចាស់សំនួរ ឃើញគាត់ពាក់អាវពណ៌ស្វាយបិទមុខនឹងស្បៃមួយផ្ទាំងពណ៌ខ្មៅមានកងតូចតឿដូចជាគ្មានអ្វីគួរឲ្យខ្លាចសោះម្ដេចក៏ទីងមិនហួសបួនភ័យម៉្លេះ ?

ខណៈនោះឮសម្លេងជួងនិងស្គរលាន់ឡើងខ្ទរ ហើយឃើញបុរសអាវលឿងម្នាក់ដើរចេញមកប្រកាស:

- លោកម្ចាស់កោះត្រកូលឡុងនិងត្រកូលមុអញ្ជើញចេញមកធ្វើបដិសណ្ឋារកិច្ចចំពោះភ្ញៀវហើយៗ អ្នកពល់គ្នាព្រឺក្បាលខ្លាក ! រហូតមកទល់នឹងពេលនេះមិនដឹងកោះឡុងមុជាអ្វីទេ ។ ឥឡូវដឹងច្បាស់ហើយថាកោះនេះមានម្ចាស់ពីរនាក់មួយត្រកូលឡុងមួយទៀតត្រកូលមុ ។

- ក្នុងគ្រាជាបន្ទាន់គេឃើញទ្វារខាងកើតបើកខ្វាកលេចមនុស្សពីរជួរដើរចេញមក ។ មួយជួរស្លៀកពាក់ខោអាវខៀវ មួយជួរទៀតស្លៀកពាក់លឿង ។ បុរសអាវខៀវម្នាក់ពោលខ្លាំងៗ :

-យើងខ្ញុំជាសិស្សគណនៃលោកម្ចាស់កោះសូមជំរាបសួរភ្ញៀវទាំងអស់ ។

ភ្ញៀវទាំងឡាយបោលភ្នែកមើលមនុស្សទាំងពីរជួរដែលមានទាបមានខ្ពស់ ឃើញចាងសានពាក់អាវលឿងឈរក្នុងជួរខាងស្ដាំត្រង់ទីដប់មួយ ។ រ៉ីលីសែ៊ពាក់អាវខៀវឈរក្នុងជួរខាងឆ្វេងទីដប់បី ។ នៅក្រោយខ្នងសេនាបញ្ញោទាំងពីររូបនេះមានមនុស្សម្ភៃបួននាក់ទៀត ។

សភាពការណ៍នេះធ្វើឲ្យអ្នកពល់គ្នាដកដង្ហើមញាប់ស្អេកទឹកថា: ចាងសាននិងលីសែ៊ខ្លាំងពូកែបែប

ណាគ្រាន់តែគាត់រួមកម្លាំងគ្នាក៏គ្មាននរណាឈ្នះទៅហើយ, ចុះចំណាំបើបងប្អូនរួមគ្រូគាត់ពីរផ្លូវនេះទៀត, តើគេពូកែដល់ថ្នាក់ណា ? អីចឹងទេតើបានជាគ្មានអ្នកក្លាហានរូបណាត្រឡប់ទៅស្រុកទេសវិញសោះ ។

ខណៈនោះសិស្សគណនៃម្ចាស់កោះឡុងបុបង្គន់ជង្គង់ព្រមគ្នាសំដែងសោគមន៍ជូនភ្ញៀវ ៗ ភ្ញៀវទាំងអស់គោរពតបវិញភ្លាមព្រមទាំងរវល់ស្រងឹងសួរក្នុងចិត្តថា :

– កាលពីងសាននិងលីសៀយកផ្កាកស្ពាន់ដើរចែកនាយក្រុមពលរូបនោះ គាត់បញ្ចេញទឹកមុខគាប់ផងសប្បាយផងពោះក្នុងពេលសម្លាប់មនុស្សក្ដីពេលដដែកគ្នាក្ដី ។ ឥឡូវមកដល់ទីតាំងកោះឡុងមុម៉េចក៏ប្រកាន់ឥរិយាបថមុឺងម៉ាត់ធ្ងើមុខស្មើបែបនេះ ?

ក្រុមតន្ត្រីចាប់បន្លឺបទយ៉ាងលន្លង់លន្លោច . . .

តាចាស់ពីរនាក់ដើរចេញមកសន្សឹមៗ ។ ម្នាក់កាន់កាវខៀវម្នាក់ទៀតកាន់កាវលឿង ។ ចុះសកាវលឿងក្នុងបន្ទប់ស្រែកទៀត :

–លោកម្ចាស់កោះឡុងមុសូមសំដែងអំណរគុណចំពោះអស់លោកគ្រប់គ្នា ។

តាចាស់ទាំងពីរក៏ឱនក្បាលបន្តិចជាកិច្ចគោរព, ឯអ្នកក្លាហានទាំងអស់ជាភ្ញៀវក៏គោរពតបវិញដែរ ។

តាចាស់កាវលឿងមានត្រកូលឡុងសើចហាសៗពោលមុនគេថា :

–ខ្ញុំបាទនិងប្អូនមុរស់នៅដាច់ស្រយាលលើកោះដ៏ខ្សត់ខ្សោយ មិនបានទទួលអស់លោកឲ្យសមរម្យទេ សូមអស់លោកអភ័យទោស ។ ថ្ងៃនេះអស់លោកអញ្ជើញមកពីគ្រប់ទិសទីពាក់ទុកជាកិត្តិយសដ៏កាសសម្រាប់បងប្អូនខ្ញុំ ។

តាចាស់ត្រកូលឡុងនិយាយដូចជនជាតិហានភាគកណ្ដាល ។ តាចាស់ត្រកូលមុពោលបន្ត:

– សូមអស់លោកអញ្ជើញអង្គុយ ។

តាចាស់រូបនេះនិយាយដូចអ្នកស្រុកក្វាងតុង ។ លុះភ្ញៀវទាំងអស់អង្គុយហើយ គាត់ដើរទៅអង្គុយនាតុមួយផ្នែកខាងក្រោម, សិស្សគណទាំងអស់ឈរអមពីក្រោយដង្ហែគ្នា ។

អ្នកក្លាហានពលរូបពិចារណា :

– ម្ចាស់កោះឡុងមុអញ្ជើញភ្ញៀវមកជប់លៀងយ៉ាងសាហាវព្រោះបើនរណារឹងទទឹង ឬប្រកែកគេសម្លាប់ចោលមួយពូជ ។ មកដល់កោះកន្លែងណាក៏បែរជាទទួលភ្ញៀវយ៉ាងកក់ទាក់គួរសមទៅវិញ ។ លុះជួបគ្នាហើយគេធ្វើម៉េចទៀតហ្ន៎ ! ចាំមើលជើងប្រួលឲ្យមែនទែន !

អ្នកខ្លះយល់ថា: មនុស្សជាប់ទោសប្រហារជីវិតត្រូវទទួលទានផ្ទៃឆ្អែតឆ្អន់មុននឹងគេនាំទៅកាត់ក្បាល យ៉ាងណាមិញម្ចាស់កោះឡុងមុះពោលពាក្យផ្អែមល្ហែមពីរបីម៉ាត់ចាំរំពុងដល់ពេលហូបបាយនោះឯង ។ មិន យូរទេ, ដល់ពេលស្ងាប់ឥឡូវហើយ ។

គេនាំគ្នាសម្លឹងមុខពិនិត្យរូបពង្វាស់កោះឡុងមុះទាំងពីររូប ។ គាឡុងស្កូវទាំងសក់ទាំងពុកមាត់ ផ្ទៃមុខគាត់ក្រហមរលោងដូចកូនក្មេង តាមពុកបន្តិចៗ ខ្លះខ្វះសខ្លះមុខជ្រីវជ្រួញសមជាចាស់មែន ។ គ្មាននរណាសន្មតបានថាគាត់មានអាយុប៉ុន្មានឡើយប្រហែលហុកសិប, កៅសិបឬជាងមួយរយក៏បានដែរ

បន្ទាប់មកទៀតអ្នកបម្រើថែងការបានជញ្ជូនស្រាជាងម្ហូបមកជូនភ្ញៀវ ដោយមួយតុៗ មានចានគោម ដាក់ម្ហូបចំកណ្ដាល, ចានសំប៉ែតដាក់ម្ហូបជូនទៀត មានតាំងពីសាច់ជ្រូក, ត្រី, បង្កង, ក្ដាមខ្យងនិងមាន់ទា ពោលគឺទន់ល្ហុយឈ្ងុយឈ្ងប់គួរស្រក់ទឹកមាត់, ដូចជាមិនឃើញស្អីគួរឲ្យសង្ស័យសោះ ។

ស៊ីផងនិយាយផង ពេលក្មេកមួយក្រុមទៀតឃើញអ្នកក្លាហាន លាំវគុនមកគ្រប់គ្នា តំហ៊ានយើងហ្វ ហ្វងលាង លីជីងជិងនិងលោកស្រីកាវសានលាងជី ។ អ្នកទាំងបួនកំពុងតែអង្គុយ ... កាលបើជួបនឹងក្មេកស៊ីផងនគេគ្រាន់តែងក់ក្បាលប៉ុណ្ណោះ ឥតហ៊ាននិយាយស្ដីចាម៉េចឡើយ

ខណៈនោះម្ចាស់កោះត្រកូលឡុងនិងមុះលើកកែវស្រាដំណាលគ្នាពោលថា:

– សុំអញ្ជើញ !

ហើយលើកពែងស្រាក្រេបមុនគេ ។ ភ្ញៀវទាំងឡាយទទួលមើលពែងរៀងខ្លួនឃើញស្រាគេ ... ទៀតថ្លា មានក្លិនក្រអូបឈ្ងុយច្រមុះគេបុកពោះភិបៗទឹកថា ស្រានេះមិនដឹងមានថ្នាំពុល សាបាវប៉ុណ្ណា ... ។ ម្ល៉ោះហើយគ្រាន់តែលើកពែងដល់បបូរមាត់បន្តិចក៏ដាក់លើតុវិញមិនហ៊ានផឹកឡើយ ។ ភ្ញៀវគានគិតទឹកថា: គេបង្សម្លាប់យើងហើយតើខ្លាចអ្វីទៀត, ទោះស្រានេះគ្មានពិសក៏ ស្លាប់ដដែលយើងត្រូវស្លាប់ឲ្យល្អមើលទើបសមជាអ្នកក្លាហាន ។

គេលើកពែងស្រាក្រេបផឹកៗទាល់តែអស់ ។ បំរើលើកប៉ាន់ចាក់ស្រាជូនភ្ញៀវទៀត ។ ម្ចាស់កោះចាក់ស្រាជូនភ្ញៀវបីដងហើយទើបតាត្រកូលឡុងលើកដៃគ្រវាសឡើងលើ ។ អ្នកបំរើ ជាច្រើននាក់ឈ្លូចេញមកលើកជាសដែលមានចានបបរតូចៗមកដាក់ជូនភ្ញៀវគ្រប់ៗគ្នា ។ អ្នកក្លាហាន ទាំងអស់នឹកដំណាលគ្នាថា នេះហើយជាបបរខែកត្តិកដែលធ្វើឲ្យអ្នកគុននិយមរាល់រូបលោះព្រលឹង ដោយគ្រាន់តែឮឈ្មោះនោះ ។

Khmer Story Lovers



បបរមួយចានៗ ហុយផ្សែងទ្រលោមនៅពុះកលៗក្នុងចានពណ៌ខៀវស្រងាត់ គ្រាន់តែឃើញក៏ ...ាលផែរ ព្រោះបបរនេះមិនដឹងធ្វើពីអ្វីទេ ដូចស្ពៃបន្តិច, ស្ពៅបន្តិច, កន្ទួងខ្លះដូចកំទេចឈ... ...ផលគេឈូស, កន្ទួងខ្លះដូចឫសឈើសំបកឈើគុម្ពខ្ចប់ផ្កាចាំងស្រស់តែម្តង ៗ អ្នកគុនគិយ... ...ាំងអស់សុទ្ធតែដឹងថាជាតិពិសពុលគ្រប់បែបយ៉ាងសុទ្ធតែមានពណ៌ខៀវឬបៃតងខ្ចី, ឯបបរនេះឡើ... ...ពណ៌ខៀវក្រមៅបែបនេះប្រាកដជាមានឥទ្ធិពលដល់កំរិតហើយ, ត្រូវនឹងក្លិនថ្នាំឆ្អួលច្រមុះទៀតពិត... ...ពិសពុលគ្រប់ប្រការនៅក្នុងចាននែន !

លោកស្រីកាវសានលាន់ដ៏គ្រាន់តែធុំក្លិនក៏ព្រឺពេបតឹង្គក់ងឹកថាបបរនេះមានតាំងពីពស់ , វ... ...យនិងពីងពាងមិនដឹងប៉ុន្មានក្បាលទេ ៗ

លោកស្រីទ្រាំមិនបាន គំរុញចានបបរទៅម្ខាង ហើយលើកដៃយកាវខ្ទប់ច្រមុះមិនឲ្យបង្ហើរ ម្ចាស់កោះត្រកូលឡុងពោលបញ្ជាក់ជូនភ្ញៀវ :

— កោះខ្ញុំបាទគ្មានម្ហូបអីថ្លៃថ្នូរទទួលអស់លោកដែលអញ្ជើញមកពីឆ្ងាយទេ, មានតែបបរមួយចា... ...នេះឯង ៗ សូមជ្រាបថា គ្រឿងផ្សំបបរអស់លោកមិនងាយរកទេ, គឺជាស្មៅផ្តាច់កោះជ្រៃ... ...ាយក្តីង, ជាស្មៅពិសេសទាល់តែផ្កាវរីគល្អទើបមានប្រយោជន៍ ៗ ប៉ុន្តែស្មៅនេះអស្ចា... ...ណាស់, ជួនកាលប្រាំឆ្នាំ, ជួនកាលរហូតដប់ឆ្នាំទើបមានផ្កាម្តង ៗ យើងខ្ញុំរង់ចាំ... ផ្កាវរីគល្អ ទើបហ៊ានអញ្ជើញអស់លោកមកភ្លក្សរសជាតិបបរពិសេស ៗ រាប់តាំងពីដូន... ...ទើបតែបានបួនដងទាំងលើកនេះទេ ៗ សូមអញ្ជើញ ! អញ្ជើញ ! កុំខ្មាសអៀន ! (នៅមានត...

ជំហល់ទុកតាមលេខ ចុះថ្ងៃទី ៦ - ៧០ . បោះពុម្ពលើកទី ១ ចំនួន ២០០០ ច្បាប់